ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៨៦/១៣-ខាលីងតុន ខេមបូឌា ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **លី តៃសេង**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខាលីងតុន ខេមបូឌា ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិរវៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

ទូរស័ព្ទ ៖ ០៩៧ ៣១៨ ៣៣ ៨៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក ហ៊ាង ប៉ចាន់ | នាយកក្រុមហ៊ុន |
| ២- លោក ឃឹម វិរៈ | ជំនួយការនាយក |
| ៣- លោក ម៉ុម ធន | អ្នកអម |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពការងារដើម្បីកម្ពុជា**

- **សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន ខាលីងតុន កម្ពុជា ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិរវៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

ទូរស័ព្ទ ៖ ០១៧ ៦៧១ ៧៩៨ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក សែម សំអឿន អនុប្រធានសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

២- លោក សាន់ ផាន់ អគ្គលេខាធិការសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

៣- កញ្ញា សឿន ជឿន អនុប្រធានសហជីពការងារដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន កាលីងតុង កម្ពុជា ខូអិលធីឌី

៤- កញ្ញា លឹម ម៉ាលី ទីប្រឹក្សាសហជីពការងារដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន កាលីងតុង កម្ពុជា ខូអិលធីឌី

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- (ទី១)-សុំឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូន ហើយបើក្រុមហ៊ុនពុំមានលទ្ធភាពទេ នោះ សុំឱ្យក្រុមហ៊ុនចេញប្រាក់ថ្លៃផ្ញើក្មេងនៅទារកដ្ឋានខាងក្រៅ ចំនួន ៥០ ដុល្លារ ក្នុង ០១ ខែ។

២- (ទី៥)-ក្រុមហ៊ុនមិនយល់ព្រមផ្តល់ថ្លៃធ្វើដំណើរ និងស្នាក់នៅចំនួន ១២ ដុល្លារ ក្នុង ០១ ខែ ជូនឡើយ។ ក្រុមហ៊ុនសុំអនុវត្តតាមច្បាប់ស្តីពីការងារ។

៣- (ទី១១)-សុំឱ្យក្រុមហ៊ុនកាត់សំលៀកបំពាក់ ០៣ សំរាប់ ក្នុង១ឆ្នាំ ជូនកម្មករ។

៤- (ទី១២)-សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលចំនួន ១២០ ដុល្លារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម លេខ ៧៥/១៣ កប/កច ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** -ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម បានទទួលបណ្តឹងសហព័ន្ធសហជីពការងារដើម្បីកម្ពុជា ទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម បានចាត់មន្ត្រីជំនាញឱ្យធ្វើការសាកសួរព័ត៌មាន និងផ្សះផ្សារតាមនីតិវិធីចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ១៤ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៧៥/១៣ កប.កច ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ១៤៖០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៤ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ២ ចំណុច គឺចំណុចវិវាទទី១ និងទី១១។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចមិនសះជា ចំនួន ២ ចំណុច ដែលនៅសល់គឺចំណុចវិវាទទី៥ និងទី១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ប្រធានក្រុមហ៊ុន កាលីងតុន (ខេមបូឌា) ខូអិលធីឌី ផ្ទេរសិទ្ធិជូនឈ្មោះ HUANG PO-CHAN ជាប្រធានរដ្ឋបាល។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះ ក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ទ្រីលាន អេធិច លីមីធីត លេខ ១៣៦៧ ពណ.ចបព ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ខាលីងតុន ខេមបូឌា ខូអិលធីឌី។

៤- សារណាសង្ខេបរបស់ក្រុមហ៊ុន ខាលីងតុន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។

៥- លិខិតអមរបស់ប្រធានក្រុមហ៊ុន ខាលីងតុន (ខេមបូឌា) ខូអិលធីឌី សុំពឹងលោក ម៉ុម ធន ជួយអមក្រុមហ៊ុននៅក្នុងរឿងក្តី ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន កាលីងតុន កម្ពុជា ខូអិលធីឌី បានចុះបញ្ជិកាលេខ ៣០៥៧ ក.ប/វក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។

២- លិខិតលេខ ៣២៦ ក.ប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពការងារដើម្បីកម្ពុជា ក្រុមហ៊ុន កាលីងតុង កម្ពុជា ខូអិលធីឌី ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត ត្រូវបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនេះតទៅ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន កាលីងតុន (ខេមបូឌា) ខូអិលធីឌី លេខ ៧៥/១៣ កប.កច ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន កាលីងតុន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១២៣៨ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១២៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខាលីតុង ខេមបូឌា ខូអិលធីឌី ជាក្រុមហ៊ុនផលិតស្បែកជើង។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបប្រមាណជា ៨៦៤ នាក់ *(យោងតាមអំណះអំណាងរបស់ភាគីនិយោជក នាថ្ងៃសវនាការអាជ្ញាកណ្តាលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣)*។
- សហជីពការងារដើម្បីកម្ពុជា ប្រចាំក្រុមហ៊ុន កាលីងតុង កម្ពុជា ខូអិលធីឌី ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះ ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជា

ជីវៈ លេខ ៣០៥៧ ក.ប/រ.ក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។ សហជីពនេះ មិនមានភាពជាតំណាងបំផុតប្រចាំក្រុមហ៊ុនទេ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិក ក្នុងមួយខែ**

- ការអនុវត្តក្នុងក្រុមហ៊ុន និយោជកផ្ដល់ប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត។
- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់បន្ថែមចំនួន ៥ ដុល្លារអាមេរិក ពោលគឺ ១២ ដុល្លារអាមេរិក ក្នុងមួយខែ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ ដែលនិយោជកបានផ្ដល់ឱ្យកម្មករនិយោជិត គឺមិនឆ្លើយតបនឹងការចំណាយលើថ្លៃឡានក្នុងការធ្វើដំណើររបស់កម្មករនិយោជិតទេ ព្រោះថា ថ្លៃឡានក្នុងការធ្វើដំណើរនេះជាមធ្យមចាប់ពី ១០ ដុល្លារអាមេរិក ក្នុងមួយខែ។
- ភាគីនិយោជកបញ្ជាក់ថា មិនមានលទ្ធភាពផ្ដល់ជូនបន្ថែមតាមការទាមទារបានទេ គឺនិយោជកសុំអនុវត្តតាមច្បាប់កំណត់។

**ចំណុចវិវាទទី ១១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ១២០ ដុល្លារអាមេរិក ក្នុងមួយខែ**

- ការអនុវត្តក្នុងក្រុមហ៊ុន និយោជកផ្ដល់ប្រាក់គោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ៨០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត។
- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្ដល់បន្ថែមប្រាក់ឈ្នួលគោល ចំនួន ៤០ ដុល្លារអាមេរិក ពោលគឺ ១២០ ដុល្លារអាមេរិក ក្នុងមួយខែ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
    - ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) មានចំនួនតិចតួច ដែលពុំអាចផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់កម្មករនិយោជិតទេ។
    - ទំនិញទាំងអស់នៅតាមទីផ្សារ មានការឡើងថ្លៃជាបន្តបន្ទាប់។
    - ប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមានការកាត់ពន្ធជូនរដ្ឋ ដែលជាហេតុនាំឱ្យប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមានចំនួនកាន់តែតិច។
- ភាគីនិយោជកបញ្ជាក់ថា មិនមានលទ្ធភាពផ្ដល់ជូនបន្ថែមតាមការទាមទារបានទេ គឺនិយោជកសុំអនុវត្តតាមច្បាប់កំណត់។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិក ក្នុងមួយខែ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចតម្លើងប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ៥ ដុល្លារអាមេរិកទៀត ក្នុងមួយខែ ទៅលើប្រាក់ចំនួន ៧ ដុល្លារអាមេរិក ក្នុងមួយខែ ដែលមានស្រាប់ដែរ ឬទេ?

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ២៣០/១២ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ចែងថា *"ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ (ប្រាំពីរ) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ ។..."* ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានផ្តល់ប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់ចំនួន ៧ ក្នុងមួយខែ ជូនកម្មករនិយោជិត ដែលការផ្តល់ឱ្យនេះ គឺតាមកំណត់នៃសេចក្តីជូនដំណឹងលេខ ២៣០ ខាងលើ ។

តាមរយៈការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានច្បាប់ បទប្បញ្ញត្តិការងារ កិច្ចព្រមព្រៀង អនុសញ្ញារួម ណាមួយរវាងនិយោជក និងភាគីកម្មករនិយោជិត ការអនុវត្តកន្លងមក ឬបទបញ្ជាផ្ទៃក្នុងដែលចែង អំពីកាតព្វកិច្ចរបស់និយោជកផ្តល់ប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ បន្ថែមទៀតលើប្រាក់សោហ៊ុយថ្លៃធ្វើដំណើរ និងថ្លៃស្នាក់ ដែលមានស្រាប់ឡើយ។ ហេតុនេះ ការទាមទារនេះ គឺជាវិវាទអំពីផលប្រយោជន៍។

ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដូចខាងក្រោម ៖

កថាខណ្ឌទី២ នៃមាត្រា ៩៦ នៃច្បាប់ស្តីពីការងារចែងថា ៖ *"អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុង មាត្រា ៩៦ កថាខ័ណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើង ដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែកគឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយឬអង្គការច្រើនតំណាងឱ្យនិយោជក*

*ខ. មួយចំណែកទៀតគឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត ។..."* ។

លើសពីនេះ ប្រការ ៩ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ *"សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចា អំពីអនុសញ្ញារួមដែលអនុវត្តចំពោះ កម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ច ត្រូវតែធ្វើការចរចាជាមួយសហជីព"*។

យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រការ៩ នៃប្រកាស ៣០៥/០១ ខាងលើ ជាទូទៅចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុត របស់សហជីព

ដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីព ផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីព ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និង មានប្រសិទ្ធភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នា លើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ"*។

យោងតាមខ្លឹមសារនៃប្រការ ៤៣ ខាងលើ សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់ បាត់បង់សិទ្ធិក្នុងការទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅមានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស *(សូមមើលសេចក្តីបង្គាប់លេខ ៨១/០៤-អេវើប្រ៊ីន ហេតុផលនៃសេចក្តីសម្រេចកចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ហ្គេត យូនៀន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣)*។

នៅក្នុងសំណុំរឿងលេខ ១៦៩/១១-ហ្វ៊ុនធ្យូនធីរ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ដោយសារសហជីពដែលនាំវិវាទការងារនោះមក ជាសហជីព ដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០២/១១-ពូយៀន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិនហានស៊ីង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១)*។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

ក្នុងករណីនេះ សហជីពការងារដើម្បីកម្ពុជានៃក្រុមហ៊ុន កាលីងតុង មិនមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុនទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិក ក្នុងមួយខែ។

**ចំណុចវិវាទទី ១១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ១២០ ដុល្លារអាមេរិក ក្នុងមួយខែ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួល

អប្បបរមា)ចំនួន ៤០ ដុល្លារអាមេរិកបន្ថែមទៀត ទៅលើប្រាក់ឈ្នួលគោល(ប្រាក់ឈ្នួលអប្បបរមា)ចំនួន ៨០ ដុល្លារ អាមេរិក ក្នុងមួយខែ ដែលមានស្រាប់ដែរ ឬទេ?

សេចក្តីជូនដំណឹងលេខ ១០៣ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រង់ចំណុចទី២ ចែងថា ៖ *"កំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន ៧៥ (ចិតសិបប្រាំ) ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតសាកល្បង ពី ១ ខែ ទៅ ៣ ខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នចំនួន ៥៦ ដុល្លារ បូកប្រាក់តម្លើងចំនួន ១៤ ដុល្លារ បូកប្រាក់ឧបត្ថម្ភថ្លៃទាំសុខភាពចំនួន ៥ ដុល្លារ ស្មើ ៧៥ ដុល្លារ) ។ ចប់រយៈពេលសាកល្បង កម្មករនិយោជិតពេញសិទ្ធិត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន ៨០ (ប៉ែតសិប) ដុល្លារអាមេរិក ក្នុងមួយខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នចំនួន ៦១ ដុល្លារ បូកប្រាក់តម្លើង ចំនួន ១៤ ដុល្លារ បូកប្រាក់ឧបត្ថម្ភថ្លៃទាំសុខភាពចំនួន ៥ ដុល្លារ ស្មើ ៨០ ដុល្លារ) ។"*

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ៨០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ដែលការផ្តល់ឱ្យនេះ គឺតាមកំណត់នៃសេចក្តីជូនដំណឹង លេខ ១០៣ ខាងលើ ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិច្បាប់ការងារ អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ ការអនុវត្តកន្លងមក ឬបទបញ្ជាផ្ទៃក្នុង ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ៤០ ដុល្លារអាមេរិក បន្ថែមទៀតលើប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ដែលមានស្រាប់ឡើយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនេះ ជាវិវាទអំពីផលប្រយោជន៍ ។ *(សូមមើលការបកស្រាយស្តីអំពីវិវាទផលប្រយោជន៍នៅក្នុង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ ខាងលើ)* ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ចំនួន ១២០ ដុល្លារអាមេរិក ក្នុងមួយខែ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១២ ដុល្លារអាមេរិក ក្នុងមួយខែ ។

**ចំណុចវិវាទទី ១១ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យ និយោជកផ្តល់ប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា)ចំនួន ១២០ ដុល្លារអាមេរិក ក្នុងមួយខែ ។

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **លី តៃសេង**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------